គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមើរ ហ្វាយនែន អិលធីឌី

FARMER FINANCE LTD Microfinance Institution

# របាយការណ៍ប្រចាំឆ្នាំ



# ២០២០

# ANNUAL REPORT

## មាតិកា

១. អំពីហ្វាមើរ ហ្វាយនែន មិលធីឌី ........ 1
១.១ សាវតាហ្វាមើរ ហ្វាយនែន មិលធីឌី ........ 1
១.២ បេសកកម្ម ........ 2
១.៣ ទស្សនៈវិស័យ ........ 2
១.៤ គុណតម្លៃស្នូល ........ 2
២.អភិបាលកិច្ច ........ 3
២.១ សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ........ 3
២.២ សាររបស់នាយកគ្រប់គ្រងទូទៅ ........ 5
២.៣ រចនាសម្ព័ន្ធ ........ 7
២.៤ ភាគទុនិក ........ 8
៣. សូចនាករលទ្ធផលសំខាន់ៗ ........ 9
៣.១ លទ្ធផលពីប្រតិបត្តិការ ........ 9
៣.២ ផលប័ត្រឥណទានប្រចាំត្រីមាសឆ្នាំ ២០២០ ........ 10
៣.៣ ការបែងចែកឥណទានតាមប្រភេទ ........ 11
៣.៤ សមិទ្ធផលឥណទានតាមវិស័យ ........ 11
៣.៥ ឥណទានមិនដំណើរការ ........ 12
៣.៦ លទ្ធផលហិរញ្ញវត្ថុ ........ 13
៤.ការគ្រប់គ្រងកិច្ចការពារសង្គម ........ 14
៤.១ ការទទួលខុសត្រូវចំពោះអតិថិជន ........ 14
៤.២ ប្រវត្តិជោគជ័យរបស់អតិថិជន ........ 15
៥. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ ........ 17
៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 17
៥.២ របាយការណ៍របស់សវនករឯករាជ្យ ........ 22
៥.៣ របាយការណ៍ហិរញ្ញវត្ថុ ........ 26
៦. សកម្មភាពសំខាន់ៗរបស់បុគ្គលិក ........ 28
៦.១ ការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក ........ 28
៦.២ ការលើកទឹកចិត្តបុគ្គលិកតាមរយៈការដើរកំសាន្តប្រចាំឆ្នាំ ........ 30
៧.តំបន់ប្រតិបត្តិការ ........ 31
៨. ដៃគូរបស់ហ្វាមើរ ហ្វាយនែន ........ 33

# ១. អំពីហ្វាមើរ ហ្វាយនែន អិលធីឌី

## ១.១ សាវតាហ្វាមើរ ហ្វាយនែន អិលធីឌី




**អគារការិយាល័យ ហ្វាមើរ ហ្វាយនែន អិលធីឌី**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្របច្បាប់នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការស្ថិតនៅផ្ទះលេខ ១០៧១ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៣ គ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរអាសយដ្ឋានទៅកាន់ផ្ទះលេខ ១៤៦៥ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

គ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរសមាសភាពទុនិកថ្មី ដែលមានការទទួលស្គាល់ពីធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧។ ក្នុងនោះដែរសមាសភាពក្រុមប្រឹក្សាភិបាល ព្រមទាំងរចនាសម្ព័ន្ធដឹកនាំមួយចំនួនក៏បានផ្លាស់ប្តូរផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** នៅតែប្រកាន់ខ្ជាប់នូវទស្សនៈវិស័យ និងគោលដៅច្បាស់លាស់ក្នុងការបំពេញតម្រូវការសេវាកម្មហិរញ្ញវត្ថុជូនប្រជាពលរដ្ឋ។ គ្រឹះស្ថានបេជ្ញាចិត្តក្នុងការបំពេញផ្នែកមួយដ៏សំ ខាន់ក្នុងសហគមន៍ ក៏ដូចជាបង្ហាញពីគោលដៅជាអ្នកចូលរួមផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ និងជួយបំពេញក្តីស្រមៃរបស់ប្រជាជនខ្មែរដែលមានបំណងចង់បង្កើតអាជីវកម្មផ្ទាល់ខ្លួន និងអភិវឌ្ឍជីវភាពរស់នៅប្រចាំថ្ងៃឲ្យកាន់តែមានភាពកាន់តែប្រសើរឡើង។

## ១.២ បេសកកម្ម



ជួយបន្តផ្គត់ផ្គង់ និងជួយទំនុកបម្រុងផ្នែកសង្គមដល់ប្រជាពលរដ្ឋដែលមានចំណូលទាបនិងសហគ្រិនខ្នាតតូច។

## ១.៣ ទស្សនៈវិស័យ



ចូលរួមកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជានិងអភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាឲ្យកាន់តែប្រសើរឡើង។

## ១.៤ គុណតម្លៃស្នូល



- គុណភាព
- ក្រមសីលធម៌
- ទំនុកចិត្ត
- ស្មារតីជាក្រុម
- ទំនួលខុសត្រូវ

## ២.អភិបាលកិច្ច

## ២.១ សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



ជាដំបូងក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល និងតំណាងឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** សូមបង្ហាញនៅការកោតសរសើរដោយស្មោះចំពោះថ្នាក់គ្រប់គ្រង ព្រមទាំងបុគ្គលិកទាំងអស់ដែលបានរួមចំនែកយ៉ាងសកម្ម ក្នុងការជម្រុញឱ្យគ្រឹះស្ថាន មិនត្រឹមតែស្ថេរភាពល្អប្រសើរនោះទេថែមទាំងរីកចម្រើនផងដែរ ទោះបីជាមានឧបសគ្គពីការរីករាលដាលនៃជំងឺកូវីដ១៩ ក៏ដោយ។ បន្ថែមលើនេះទៀតនាងខ្ញុំក៏សូមបង្ហាញនូវសេចក្តីថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នបញ្ញត្តិករនានា ជាពិសេសធនាគារជាតិ នៃកម្ពុជាដែលបានជួយគាំទ្រវិស័យហិរញ្ញវត្ថុទាំងមូលនិយាយជារួមនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** និយាយដោយឡែក ដែលធ្វើឱ្យវិស័យទាំងមូលមានស្ថេរភាពគួរឱ្យកត់សំគាល់ក្នុងឆ្នាំ ២០២០ នេះ។ មិនតែប៉ុណ្ណោះក៏សូមអរគុណដល់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក៏ដូចជាអតិថិជនទាំងអស់ដែលតែងតែជួយគាំទ្រ យោគយល់ សហការជាមួយគ្រឹះស្ថានរបស់យើងកន្លងមក។

ការរីករាលដាលនៃជំងឺកូវីដ១៩ នៅលើពិភពលោកក្នុងឆ្នាំ២០២០ នេះបានធ្វើឱ្យមានការផ្លាស់ប្តូររបៀបនៃការរស់នៅ ទំនាក់ទំនងសង្គម សុខភាពសាធារណៈ និងដំណើរការសេដ្ឋកិច្ចសកលផងដែរ។ នៅប្រទេសកម្ពុជា ការអូសបន្លាយនៃការរីករាលដាលនេះបានបង្កើតឱ្យមានវិបត្តិដល់វិស័យធំៗមួយចំនួនគួរឱ្យព្រួយបារម្ភ ក៏ប៉ុន្តែវិស័យធនាគារ និងហិរញ្ញវត្ថុ គឺនៅតែរក្សាបាននូវស្ថេរភាព និងអាចឈរជើងបាននៅលើទីផ្សារ។ យើងឃើញថាទ្រព្យសកម្មនៅក្នុងប្រព័ន្ធធនាគារមានរហូតដល់ ២១៧% នៃ ផលិតផលដុលក្នុងស្រុកសរុប (GDP) ជាមួយកំណើនប្រចាំឆ្នាំ ១៥,៧%។ បន្ថែមលើនេះទៅទៀត ឥណទានផ្តល់ជូនអតិថិជនមានរហូតដល់ ១៤០% នៃផលិតផលក្នុងស្រុកសរុបជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ ១៦,៩% ចំណែកឯចំនួនប្រាក់បញ្ញើរអតិថិជនវិញមានអត្រាកំណើនជាមធ្យមចំនួន ១៥,៤% ស្មើនឹង ១២៣% នៃផលិតផលក្នុងស្រុកសរុប នេះបើតាមរបាយការណ៍របស់ធនាគារជាតិ នៃកម្ពុជា។

នៅតែភាពស្រពិចស្រពិលនៃការបញ្ចប់នូវការរីករាលដាលនៃជំងឺកូវីដ១៩ ទោះបីជាមានវ៉ាក់សាំងមួយចំនួនត្រូវបានអនុម័តឱ្យប្រើប្រាស់បន្ទាន់ដោយអង្គការសុខភាពពិភពលោកក៏ដោយ ក៏ប៉ុន្តែការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ថាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងមានកំណើនចំនួន ៤% ដូចៗគ្នា នៅក្នុងឆ្នាំ ២០២១ ខាងមុខនេះ។

ស្របជាមួយគ្នានេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** បានត្រៀមខ្លួនជាស្រេចនៅក្នុងការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់ប្រជាជន ដោយពួកយើងនឹងខិតខំបង្កើតនូវជម្រើសហិរញ្ញវត្ថុបន្ថែម និងផ្តល់សេវាកម្មប្រាក់កម្ចីក្នុងអត្រាការប្រាក់ដ៏ប្រសើរជាងមុន ដើម្បីបំពេញតម្រូវការអតិថិជន ក៏ដូចជារួមចំណែកក្នុងការជួយឱ្យសេដ្ឋកិច្ចជាតិមានកំណើនទោះស្ថិតក្នុងស្ថានភាពនៃវិបត្តិកូវីដ១៩ នេះក្តី។

ជាចុងក្រោយ នាងខ្ញុំរួមទាំងគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់នឹងបន្តការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តបំពេញការងារក្នុងគោលបំណងដើម្បីឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** ក្លាយជាគ្រឹះស្ថានដែលឈានមុខមួយ ក្នុងចំណោមគ្រឹះស្ថានដែលឈានមុខទាំងអស់នៅកម្ពុជា។

**ហត្ថលេខា និងត្រា**

**ប្រធានក្រុមប្រឹក្សាភិបាល**

ហ្វាមើរ ហ្វាយនែន. អិលធីឌី
"អេហ្វ អេហ្វ"
FARMER FINANCE LTD.
"FF"

លី_បុផា

## ២.២ សាររបស់នាយកគ្រប់គ្រងទូទៅ



ឆ្នាំ ២០២០ គឺជាឆ្នាំពោពេញទៅដោយការប្រកួតប្រជែងជាពិសេសការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ ១៩។ ជំងឺកូវីដ១៩ បានផ្ទុះឡើងក្នុងឆ្នាំ ២០១៩ និងបានរីករាលដាលពាសពេញពិភពលោកនៅក្នុងឆ្នាំ ២០២០ ដែលបានធ្វើឱ្យមានផលប៉ះពាល់ជាខ្លាំងដល់សេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុសកលលោក។ ដូចទៅនឹងប្រទេសផ្សេងៗទៀតដែរ ប្រទេសកម្ពុជាក៏រងនូវផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩ នេះដែរ ដែលបានធ្វើឱ្យអត្រាកំណើនសេដ្ឋកិច្ចក្នុងប្រទេសចេញសញ្ញាអវិជ្ជមាន ដែលខុសពីឆ្នាំកន្លងមកដែលមានអត្រាកំណើនជាមធ្យមពី ៧% ទៅ ៨%។ ក្នុងឆ្នាំ ២០២០ នេះដែរយើងឃើញថាវិស័យធំៗដែលរងផលប៉ះពាល់ខ្លាំងនោះរួមមាន៖ វិស័យទេសចរណ៍ វិស័យកាត់ដេរ និងវាយនភ័ណ្ឌ និងវិស័យសំណង់ជាដើម។ ទោះបីជាមានផលប៉ះពាល់លើវិស័យមួយចំនួនក្តី តែបើក្រឡេកមើលវិស័យហិរញ្ញវត្ថុនៅកម្ពុជាវិញគឺថាមានស្ថេរភាពល្អប្រសើរ និងនៅតែបន្តឈរជើងនៅលើទីផ្សារបានផងដែរ ទោះយ៉ាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** គឺនៅតែអាចបន្តការរីកចម្រើនរបស់ខ្លួនបានគួរឱ្យកត់សម្គាល់។

គិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២០ ផលប័ត្រឥណទានមានចំនួន ២.១៦២.២១៣ ដុល្លារអាមេរិក កើនឡើងចំនួន ៥៩% បើធៀបនឹងឆ្នាំ ២០១៩ ចំណែកឯអតិថជនសកម្មសរុបវិញមានចំនួន ៣៩១ នាក់ កើនឡើងចំនួន ១៧% តែប៉ុណ្ណោះបើធៀបនឹងឆ្នាំ ២០១៩។ ទន្ទឹមនឹងការកើនឡើងនៃផលប័ត្រឥណទាន និងអតិថិជនសកម្មនេះដែរ យើងកត់សម្គាល់ឃើញថាឥណទានមិនដំណើរការក៏មានការកើនឡើងផងដែរ ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ ១៩ នេះ ធ្វើឱ្យអតិថិជនរបស់យើងបាត់បង់មុខរបរ ផ្អាកសកម្មភាពអាជីវកម្ម ដែលបណ្តាលឱ្យបាត់បង់ប្រាក់ចំណូល។ ក្នុងឆ្នាំ ២០២០ នេះ ឥណទានមិនដំណើការគឺ ១,៦២% ដែលកាលពីចុងឆ្នាំ ២០១៩ មិនមានឥណទានមិនដំណើរសោះ។ ពាក់ព័ន្ធជាមួយនឹងជំងឺកូវីដ១៩ នេះដែរ ដើម្បីជួយសម្រួលដល់អតិថិជនដែលរងផលប៉ះពាល់ គ្រឹះស្ថានបានធ្វើឥណទានរៀបចំឡើងវិញជូនដល់អតិថិជន ១៣៥ នាក់ នៅក្នុងឆ្នាំ ២០២០ នេះ។ បន្ថែមលើនេះទៀតគ្រឹះស្ថានប្តេជ្ញានឹងនៅតែចូលរួមគាំទ្រអតិថិជនរបស់ខ្លួនក្នុងការទទួលបានឥណទានបន្ថែមដើម្បីពង្រឹងសេដ្ឋកិច្ចគ្រួសារ ក៏ដូចជារៀបចំឥណទានឡើងវិញជូនអតិថិជនដែលរងផលប៉ះពាល់ខ្លាំងបន្ថែមទៀតនៅក្នុងឆ្នាំ ២០២១ខាងមុខនេះ។

តាងនាមឱ្យគណៈគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី** សូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រដល់ថ្នាក់គ្រប់គ្រងតាមនាយកដ្ឋាននីមួយៗ ព្រមទាំងបុគ្គលិកទាំងអស់ដែលបានខិតខំពុះពារប្រឹងប្រែង និងប្តេជ្ញាចិត្តខ្ពស់ក្នុងការជំនះឧបសគ្គដ៏លំបាកនេះ រហូតទទួលបានលទ្ធផលមួយដែលទទួលយកបាន។ ហើយក៏សូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលបានគាំទ្រ និងផ្តល់អនុសាសន៍ល្អៗ ដែលជំរុញឱ្យគ្រឹះស្ថានមានការរីកចម្រើនទៅមុខបន្ថែមទៀត។

**ហត្ថលេខា**

ឃួយ_វណ្ណធី

## ២.៣ រចនាសម្ព័ន្ធ


ហ្វាមើរ ហ្វាយនែន អិលធីឌី
FARMER FINANCE LTD
រចនាសម្ព័ន្ធ
ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មការគ្រប់គ្រងហានិភ័យ
គណៈកម្មការសវនកម្ម
នាយកគ្រប់គ្រងទូទៅ
នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានព័ត៌មានវិទ្យា
នាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល
នាយកដ្ឋានសវនកម្ម
មន្ត្រីប្រតិបត្តិតាម
ប្រធានឥណទាន
មន្ត្រីព័ត៌មានវិទ្យាជាន់ខ្ពស់
ប្រធានគណនេយ្យករ
ប្រធានបេឡាករ
មន្ត្រីធនធានមនុស្សជាន់ខ្ពស់
មន្ត្រីសវនករផ្ទៃក្នុង
ជំនួយការឥណទាន
ប្រធានមន្ត្រីឥណទាន
ប្រធានមន្ត្រីឥណទាន
ជំនួយការគណនេយ្យ
បេឡាករ
បេឡាករ
មន្ត្រីរដ្ឋបាល
អនាម័យ
មន្ត្រីឥណទាន

## ២.៤ ភាគទុនិក



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្របច្បាប់នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៨ ដែលមានទីស្នាក់ការស្ថិតនៅផ្ទះលេខ ១០៧១ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ គ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរអាសយដ្ឋានទៅកាន់ផ្ទះលេខ ១៤៦៥ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

គ្រឹះស្ថានបានធ្វើការផ្លាស់ប្តូរសមាសភាពភាគទុនិកថ្មី ដែលមានការទទួលស្គាល់ពីធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧។

| ភាគទុនិក | ចំនួនភាគហ៊ុន | តម្លៃ (គិតជាដុល្លារ) | ភាគរយ |
|---|---|---|---|
| កញ្ញា លី បូផា | ១៥.០០០ | ១.៥០០.០០០ | ១០០% |
| **សរុប** | **១៥.០០០** | **១.៥០០.០០០** | **១០០%** |

## ៣. សូចនាករលទ្ធផលសំខាន់ៗ

### ៣.១ លទ្ធផលពីប្រតិបត្តិការ

| បរិយាយ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| **លទ្ធផលពីប្រតិបត្តិការ** | | | |
| ផលប័ត្រឥណទានសរុប (គិតជាដុល្លារអាមេរិក) | ២.១៦២.២១៣ | ១.៣៦២.២១៨ | ៤៧៤.៨៣៩ |
| អតិថិជនសកម្ម | ៣៩១ | ៣៣៣ | ១៩៥ |
| ចំនួនអតិថិជនជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ | ៤៩ | ៥៦ | ២៥ |
| ផលប័ត្រឥណទានជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ | ២៧៣.៩៦២ | ២២៧.០៣៦ | ៥៩.៣៥៤ |
| ទំហំឥណទានជាមធ្យម (គិតជាដុល្លារអាមេរិក) | ៥.៦០៥ | ៤.០៩០ | ២.៤៣៥ |
| ផលប័ត្រឥណទានស្ថិតក្នុងហានិភ័យ (គិតជាភាគរយ) | ១.៦២% | 0% | 0.៦% |

នៅបំណាច់ឆ្នាំ ២០២០ **ហ្វាមើរ ហ្វាយនែន** មានផលប័ត្រឥណទានសរុបគិតជាប្រាក់ដុល្លារអាមេរិក ចំនួន ២.១៦២.១២៣ ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ ២០១៩ មានចំនួន ១.៣៦២.២១៨ ដុល្លារអាមេរិក កើនឡើងចំនួន ៧៩៩.៩០៥ ដុល្លារអាមេរិក ចំណែកឯចំនួនអតិថិជនសកម្មវិញគឺមានការកើនឡើងចំនួន ៥៨នាក់ ដោយក្នុងឆ្នាំ ២០១៩ មានចំនួនតែ ៣៣៣នាក់ និងឆ្នាំ ២០២០ មានចំនួនរហូត ៣៩១នាក់។



## ៣.២ ផលប័ត្រឥណទានប្រចាំត្រីមាសឆ្នាំ ២០២០



ផលប័ត្រឥណទានប្រចាំត្រីមាសក្នុងឆ្នាំ២០២០ មានការកើនឡើងជាលំដាប់។ នៅក្នុងត្រីមាសទី១ ផលប័ត្រឥណទានមានចំនួន ១.៦០០.២៨៦ ដុល្លារអាមេរិក នៅត្រីមាសទី២ ផលប័ត្រឥណទានមានចំនួន ១.៦៣១.៧២៩ ដុល្លារអាមេរិក មានការកើនឡើងចំនួន ២% ធៀបនឹងត្រីមាសទី១ ចំណែកឯត្រីមាសទី៣ ផលប័ត្រឥណទានមានចំនួន ១.៨៤២.៤៨០ ដុល្លារអាមេរិក មានការកើនឡើងចំនួន ១៣% បើធៀបនឹងត្រីមាសទី២ ចំពោះត្រីមាសទី៤ វិញផលប័ត្រឥណទានមានចំនួន ២.១៦២.២១៣ ដុល្លារអាមេរិក មានការកើនឡើង ១៧% បើធៀបនឹងត្រីមាសទី៣។



## ៣.៣ ការបែងចែកឥណទានតាមប្រភេទ

ដើម្បីបង្ករលក្ខណៈងាយស្រួលក្នុងការបំពេញតម្រូវការរបស់អតិថិជន គ្រឹះស្ថានបានបង្កើតឱ្យមាននូវផលិតផល ឥណទានសម្បូរបែប ងាយស្រួល និងបំពេញសេចក្តីត្រូវការរបស់អតិថិជនជាទូទៅ។ នៅក្នុងឆ្នាំ ២០២០ ផលិតផលឥណទានដែលទទួលបានការគាំទ្រច្រើនជាងគេគឺផលិតផលឥណទានឯកកត្តជន ដែលមានចំនួនស្មើនឹង ៦៣% នៃឥណទានសរុប បន្ទាប់មកគឺផលិតផលឥណទានហ្វាមើរហ្វាយនែន ២៩% ផលិតផលឥណទានទូទៅ ២% ផលិតផលឥណទានបុគ្គលិក ២% និងផលិតផលឥណទានផ្សេងៗ ៤% ។




## ៣.៤ សមិទ្ធផលឥណទានតាមវិស័យ

នៅក្នុងឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** បានផ្តល់ជូនឥណទានទៅកាន់វិស័យចំនួន ៨ ដែលក្នុងនោះរួមមានមានវិស័យសេវាកម្មចំនួន ៤៤.៧៦% វិស័យគ្រួសារចំនួន ២៤.០៤% វិស័យពាណិជ្ជកម្មចំនួន ១៦.៨៨% វិស័យសំណង់ចំនួន ៥.៣៧% វិស័យមន្ត្រីរាជការចំនួន ៥.៦៣% វិស័យកសិកម្មចំនួន ១.៥៣% វិស័យដឹកជញ្ជូនចំនួន ១.២៨% និងវិស័យផ្សេងៗទៀតចំនួន ០.៥១%។



## ៣.៥ ឥណទានមិនដំណើរការ




សំពៀតឥណទាន(PAR) មានចំនួន ០.៦១% នៅចុងឆ្នាំ២០១៨ ត្រូវបានដោះស្រាយមកនៅ 0% នៅចុងឆ្នាំ២០១៩ ដោយឡែកនៅចុងឆ្នាំ២០២០ សំពៀតឥណទានមានចំនួន ១.៦២% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៩ មានការកើនឡើងដោយសារផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩ បន្តអូសបន្លាយដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពសងត្រលប់របស់អតិថិជនមួយចំនួន។



## ៣.៦ លទ្ធផលហិរញ្ញវត្ថុ

| លទ្ធផលហិរញ្ញវត្ថុ | | | |
|---|---|---|---|
| បរិយាយ | ២០២០ | ២០១៩ | ២០១៨ |
| ចំណូលប្រតិបត្តិការសរុប (គិតជាដុល្លារអាមេរិក) | ២៩១.៥៩៩ | ២១៨.២៩៥ | ១១៧.៨៨០ |
| ចំណាយប្រតិបត្តិការសរុប (គិតជាដុល្លារអាមេរិក) | ២៨៣,៤៨៨ | ២២៧.១៥២ | ១២៧.៣២៦ |
| ប្រាក់ចំណេញ/ខាតសុទ្ធ (គិតជាដុល្លារអាមេរិក) | ៣៧.២៣៩ | (៤.០២៨) | (៤១.៨៩៥) |
| ទ្រព្យសកម្មសរុប (គិតជាដុល្លារអាមេរិក) | ២.៣៦១.៣៧០ | ១.៥៣០.២៦១ | ១.៣០៦.៦៦៣ |
| ទ្រព្យអកម្មសរុប (គិតជាដុល្លារអាមេរិក) | ១.០០៤.៤៧៥ | ២៣៣.២៣៦ | ៥.៦១០ |
| ដើមទុន (គិតជាដុល្លារអាមេរិក) | ១.៣៣៤.២៦៤ | ១.២៩៧.០២៥ | ១.៣០១.០៥៣ |
| ចំណូលធៀបនឹងមូលធន | ២,៧៩% | (០.៣១%) | (៣.២២%) |
| ចំណូលធៀបនឹងទ្រព្យសកម្ម | ១,៥៨% | (០.២៦%) | (៣.២០%) |



# ៤.ការគ្រប់គ្រងកិច្ចការពារសង្គម

## ៤.១ ការទទួលខុសត្រូវចំពោះអតិថិជន



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** មានគោលការណ៍ច្បាស់លាស់ក្នុងការផ្តល់ប្រាក់កម្ចីដល់អតិថិជនដោយឆ្លងកាត់ការធ្វើបទសម្ភាសន៍ដើម្បីស្វែងយល់ពីប្រវត្តិនៃការរស់នៅ ការប្រាស្រ័យទាក់ទងជាមួយប្រជាជននិងអាជ្ញាធរក្នុងតំបន់ ប្រវត្តិនៃការខ្ចីប្រាក់ និងចំណូលចំណាយប្រចាំថ្ងៃជាដើម។ គ្រប់អតិថិជនទាំងអស់ដែលបានខ្ចីប្រាក់ពីគ្រឹះស្ថានត្រូវបានយកទៅប្រើប្រាស់ចំគោលដៅ និងប្រើប្រាស់ដោយមានប្រសិទ្ធភាព កត្តាទាំងនេះហើយដែលធ្វើឱ្យអតិថិជនមានជីវភាពប្រសើរឡើង ដែលឆ្លុះបញ្ចាំងពីទំនួលខុសត្រូវរបស់គ្រឹះស្ថានចំពោះអតិថិជន។

## ៤.២ ប្រវត្តិជោគជ័យរបស់អតិថិជន



(លោកស្រី ងួន សុភាព អ្នកលក់បាយគុយទាវ)

**លោកស្រី ងួន សុភាព**
**(អ្នកលក់អាហារពេលព្រឹក)**

លោកស្រី ងួន សុភាព អាយុ ៤២ ឆ្នាំ ជាម្តាយមានកូន២នាក់ ស្រី ១នាក់ និងប្រុស ១នាក់ រស់នៅភូមិទួលរការ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ លោកស្រីមានមុខរបរលក់អាហារពេលព្រឹកនៅផ្ទះ។ លោកស្រីប្រកបមុខរបរនេះជិតដប់ឆ្នាំមកហើយ។ ប្តីរបស់លោកស្រីឈ្មោះ លឹម គឹមឈា ធ្វើការក្នុងរោងពុម្ពអោយក្រុមហ៊ុនឯកជន។ គាត់មានបទពិសោធន៍នៅក្នុងការងាររបស់ គាត់អស់រយៈពេលជាងជាងដប់ឆ្នាំមក ហើយ។

លោកស្រី ងួន សុភាព ស្គាល់ **ហ្វាមើរ ហ្វាយនែន** ជាលើកដំបូងនៅឆ្នាំ២០១៣ តាមរយៈការផ្សព្វផ្សាយរបស់មន្ត្រីឥណទានរបស់គ្រឹះស្ថានដែលបានចុះផ្សព្វផ្សាយណែនាំពីផលិតផល និងសេវាកម្មជូនលោកស្រីនៅក្នុងភូមិ។ លោកស្រីបានខ្ចីប្រាក់កម្ចីពី **ហ្វាមើរ ហ្វាយនែន** ដើម្បីធ្វើដើមទុន និងទិញសម្ភារៈលក់អាហារពេលព្រឹកនៅផ្ទះរបស់គាត់។ លោកស្រីបានមានប្រសាសន៍ថា លោកស្រីទុកចិត្ត **ហ្វាមើរ ហ្វាយនែន** ដោយសារតែសេវាកម្មហិរញ្ញវត្ថុរបស់ ហ្វាមើរ ហ្វាយនែន តែងតែឆ្លើយតបទៅនឹងតម្រូវការរបស់លោកស្រីគ្រប់ពេល។ លោកស្រីបានបន្តប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុរបស់ **ហ្វាមើរ ហ្វាយនែន** ជាបន្តបន្ទាប់ ដែលរហូរមកទល់ពេលនេះ លោកស្រីជាអតិថជនរបស់ ហ្វាមើរ ហ្វាយនែន អស់រយៈពេល ៩វគ្គហើយ។ ក្រៅពីលក់អាហារពេលព្រឹក លោកស្រីអាចពេលមើលថៃរផ្ទះសំបែង និងកូនៗរបស់អ្នកស្រីដែលធ្វើអោយគ្រួសារអ្នកស្រី រស់នៅប្រកបដោយសុភមង្គល។

មុនពេលប្រើសេវាកម្មហិរញ្ញវត្ថុរបស់ **ហ្វាមើរ ហ្វាយនែន** លោកស្រីពឹងផ្អែកទាំងស្រុងទៅលើប្រាក់ចំណូលរបស់ស្វាមី។ ឥឡូវនេះគ្រួសារលោកស្រី រកបានប្រាក់ចំណូលកើនឡើងជាងមុនដោយសារតែលោកស្រីមានអតិថិជនកាន់តែច្រើនមកទទួលទានអាហាររបស់លោកស្រី ធ្វើអោយជីវភាពរបស់គ្រួសារលោកស្រីកាន់តែប្រសើឡើង។ លោកស្រី ងួន សុភាព មានបំណងចង់កែលំអរអាជីវកម្មបន្ថែមទៀតនៅថ្ងៃអនាគត។ លោកស្រីមានប្រសាសន៍បន្ថែមថា "ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលបានទទួលឥណទានរបស់ **ហ្វាមើរ ហ្វាយនែន អិលធីឌី** និងសូមអរគុណចំពោះ **ហ្វាមើរ ហ្វាយនែន** ដែលបានជួយដល់មុខរបរ និងគ្រួសាររបស់យើងខ្ញុំ បានរីកចម្រើន"។

## លោកស្រី ផេង សុវណ្ណនី (ម្ចាស់ដេប៉ូលក់គ្រឿងភេសជ្ជៈ និងម្ចាស់ហាងកាហ្វេ Orkide Coffee)



**លោកស្រី ផេង សុវណ្ណនី** ជាមួយនឹងស្នាមញញឹមពោពេញទៅដោយក្តីសង្ឃឹម លោកស្រីមានអាយុ ២៨ឆ្នាំ មានកូនស្រី ១នាក់ រស់នៅក្នុងភូមិព្រៃកធន ឃុំព្រៃកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។ លោកស្រីមានមុខរបរជាអ្នកលក់ភេសជ្ជៈបោះដុំនៅផ្ទះរបស់លោកស្រី។ លោកស្រីមានបទពិសោធន៍លើមុខរបរនេះប្រាំឆ្នាំមកហើយ។ ប្តីរបស់លោកស្រីគឺជាបុគ្គលិកបំរើការងារខាងផ្នែកព័ត៌មានវិទ្យាអោយក្រុមហ៊ុនឯកជនមួយ។

**លោកស្រី ផេង សុវណ្ណនី** បានស្គាល់ **ហ្វាមើរ ហ្វាយនែន** ជាលើកដំបូងក្នុងឆ្នាំ ២០២០ តាមរយៈប្តី របស់លោកស្រី។ ដោយមើលឃើញនូវសក្តានុពលនៅក្នុងតំបន់របស់លោកស្រី គាត់សម្រេចចិត្តស្នើសុំប្រាក់កម្ចីចំនួន ២០.០០០ ដុល្លារ ដើម្បីបើកហាងកាហ្វេដែលមានឈ្មោះថា "Orkide Coffee"។ បន្ទាប់ពីទទួលបានប្រាក់កម្ចី គ្រួសារលោកស្រីបានចាប់ផ្តើមអាជីវកម្មថ្មីបន្ថែមលើមុខរបរចាស់ ដែលធ្វើឱ្យលោកស្រីបានប្រាក់ចំណូលបន្ថែម និងមានលទ្ធភាពសងប្រចាំខែយ៉ាងងាយស្រួល។

ជាមួយនឹងប្រាក់ចំណូលដែលលោកស្រីរកបានអាចធ្វើអោយជីវភាពគ្រួសារលោកស្រីមានភាពល្អប្រសើរជាងមុន និងធ្វើឱ្យអតិថិជនកាន់តែច្រើនឡើងមកជួយទិញភេសជ្ជៈនៅដេប៉ូរបស់លោកស្រី។ នៅពេលអនាគត លោកស្រី ចង់ឃើញមុខរបរលោកស្រីកាន់តែមានភាពប្រសើរឡើង និងចង់ជួយទំនុកបំរុងដល់ការសិក្សារបស់កូនលោកស្រីអោយបានខ្ពង់ខ្ពស់។

លោកស្រីមានប្រសាសន៍ថា "ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលបានទទួលឥណទានរបស់ **ហ្វាមើរ ហ្វាយនែន** និងសូមអរគុណចំពោះ **ហ្វាមើរ ហ្វាយនែន** ដែលបានជួយដល់មុខរបរ និងគ្រួសាររបស់យើងខ្ញុំ បានរីកចម្រើន"។

# ៥. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

## ៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វាមើរ ហ្វាយនែន អេហ្វ អេហ្វ** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀតដល់អតិថិជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ៣០.៦៤៨ | ១២៤.៩៥៣ | ២៨០ | ១.១៣៥ |
| (ឥណទាន)/ចំណាយពន្ធលើប្រាក់ចំណេញ | ៤.៧៧២ | ១៩.៤៥៥ | (៤.៣០៨) | (១៧.៤៥៦) |
| ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ | ៣៥.៤២០ | ១៤៤.៤០៨ | (៤.០២៨) | (១៦.៣២១) |

### ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

### ដើមទុន

ដើមទុន ដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២០ មានចំនួន ១,៥០០,០០០ដុល្លារអាមេរិក (២០១៩: ១.៥០០០.០០០) ដុល្លារអាមេរិក ដែលក្នុងនោះមួយភាគហ៊ុនមានតម្លៃស្មើនឹង ១០០ ដុល្លារអាមេរិក។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ក្រៅពីបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជា សារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

**ការផ្លាស់ប្តូរនៃហេតុការណ៍**

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| កញ្ញា លី បូផា | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក អ៊ុក តូរ៉ូណា | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០) |
| លោក ឃួយ វណ្ណទី | អភិបាល (តែងតាំងនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០) |
| លោក តុង វតនាវរដា | អភិបាល (លាលែងនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០) |
| កញ្ញា ឃី សុខា | អភិបាល (លាលែងនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

កញ្ញា លី បូផាកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន ១០០ ភាគរយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយ ក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និងព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម") CIFRS for SMEs")។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្នព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMES ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញពីភាពពិតនិងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូល

ដ្ឋាននិរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី ១០ ដល់ ៤៩ ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

ហ្វាមើរ ហ្វាយនែន លីមីធីត "អេហ្វ អេហ្វ" FARMER FINANCE LTD. "F.F"

_______________________

កញ្ញា លី បូផា

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១

## ៥.២ របាយការណ៍របស់សវនករឯករាជ្យ

### ជូនចំពោះភាគទុនិក
### ហ្វាមើរ ហ្វាយនែន អិលធីឌី

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ហ្វាមើរ ហ្វាយនែន "អេហ្វ អេហ្វ" ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំគឺឯករាជ្យពីក្រុមហ៊ុន តាមតម្រូវការនៃក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជា មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២០ ថារបាយការណ៍នោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឲ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការមានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះអាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវ រាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ

ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើង ដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គង តែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវភាពយកចិត្តទុកដាក់ក្នុងអំឡុងពេលសវនកម្ម។

យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។

- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាននិងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។
- យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ចំពោះកត្តាពាក់ពន្ធ័ពីសវនកម្មរួមមានជាអាទិ៍ វិសាលភាពនិងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងបញ្ហាជាសារវន្តរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ&អឹសូស៊ីអេត**

ហេង សិតា

*នាយកគ្រប់គ្រង*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២១

## ៥.៣ របាយការណ៍ហិរញ្ញវត្ថុ

### របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
### នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៥.៨៥៣ | ១៨៥.៤៧៥ | ៣៤.៧១៩ | ១៤១.៤៨០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៧៨.៣៣១ | ៣១៦.៨៤៩ | ៧៥.៥៨៥ | ៣០៨.០០៩ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ១៩.៥៩៤ | ៧៩.២៥៨ | ២០.២៩៩ | ៨២.៧១៨ |
| ឥណទានផ្តល់ដល់អតិថិជន | ២.១៦២.២១៣ | ៨.៧៤៦.១៥២ | ១.៣៦២.២១៨ | ៥.៥៥១.០៣៨ |
| ទ្រព្យសកម្មផ្សេងៗ | ១៥.៤០២ | ៦២.៣០១ | ៦.៤៤៦ | ២៦.២៦៨ |
| ទ្រព្យ និងបរិក្ខារ | ៣៣.៧៩៣ | ១៣៦.៦៩៣ | ២៩.០៥៧ | ១១៨.៤០៧ |
| ទ្រព្យសកម្មអរូបី | - | - | ៧១ | ២៨៩ |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | ៦.១៨៤ | ២៥.០១៣ | ១.៨៦៦ | ៧.៦០៤ |
| **ទ្រព្យសកម្មសរុប** | ២.៣៦១.៣៧០ | ៩.៥៥១.៧៤១ | ១.៥៣០.២៦១ | ៦.២៣៥.៨១៣ |
| | | | | |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | ២២.២០៨ | ៨៩.៨៣១ | ៣២.២៧០ | ១៣១.៥០០ |
| ប្រាក់កម្ចី | ១.០០៤.៤៧៥ | ៤.០៦៣.១០១ | ២០០.៣៧៣ | ៨១៦.៥២០ |
| បំណុលពន្ធអប្បបរមា | - | - | ៥៩៣ | ២.៤១៦ |
| **បំណុលសរុប** | ១.០២៧.១០៦ | ៤.១៥៤.៦៤៣ | ២៣៣.២៣៦ | ៩៥០.៤៣៦ |
| | | | | |
| **មូលធន** | | | | |
| ដើមទុន | ១.៥០០.០០០ | ៦.០០០.០០០ | ១.៥០០.០០០ | ៦.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - |
| ប្រាក់ខាតបង្គរ | (១៦៥.៧៣៦) | (៦៦៧.៨៨០) | (២០២.៩៧៥) | (៨១៩.៧០៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៦៤.៩៧៨ | - | ១០៥.០៨១ |
| **មូលធនសរុប** | ១.៣៣៤.២៦៤ | ៥.៣៩៧.០៩៨ | ១.២៩៧.០២៥ | ៥.២៨៥.៣៧៧ |
| **មូលធន និងបំណុលសរុប** | ២.៣៦១.៣៧០ | ៩.៥៥១.៧៤១១ | ១.៥៣០.២៦១ | ៦.២៣៥.៨១៣ |

## របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | | | | |
| | ៣១២.៧២៣ | ១.២៧៤.៩៧២ | ១៤៨.១៩៧ | ៦០០.៤៩៤ |
| ចំណាយលើការប្រាក់ | (៤៩.៣៦៨) | (២០១.២៧៣) | (៦៦៦) | (២.៦៩៩) |
| **ចំណូលពីការប្រាក់សរុប** | ២៦៣.៣៥៥ | ១.០៧៣.៦៩៩ | ១៤៧.៥៣១ | ៥៩៧.៧៩៥ |
| | | | | |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៨.២៤៤ | ១១៥.១៥១ | ៧០.០៨៩ | ២៨៤.០៣៧ |
| **ចំណូលប្រតិបត្តិការសរុប** | ២៩១.៥៩៩ | ១.១៨៨.៨៥០ | ២១៧.៦២៩ | ៨៨១.៨៣២ |
| | | | | |
| ចំណាយលើប្រាក់បៀវត្សរ៍ | (១៥៨.៨០២) | (៦៤៧.៤៣៦) | (១១៣.៣៥០) | (៤៥៩.២៩៤) |
| រំលស់ | (១១.៣៣១) | (៤៦.១៩៦) | (១៤.១៦០) | (៥៧.៣៧៦) |
| ចំណាយទូទៅ និងរដ្ឋបាល | (៦៣.៩៨៧6) | (២៦០.៨៧៥) | (៩៨.៩៧៦) | (៤០១.០៥១) |
| (តំហយ)/ការខាតបង់លើឱនភាពនៃ ឥណទានផ្តល់ដល់អតិថិជន | (២១.១៤៨) | (៨៦.២២០) | ១១.៨០០ | ៤៧.៨១៤ |
| ចំណាយពន្ធអប្បបរមា | (៣.៤១០) | (១៣.៩០៣) | (២.៦៦៣) | (១០.៧៩០) |
| **ប្រាក់ចំណេញមុនដកពន្ធ** | ៣២.៩២១ | ១៣៤.២២០ | ២៨០ | ១.១៣៥ |
| | | | | |
| ឥណទាន/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ៤.៣១៨ | ១៧.៦០៤ | (៤.៣០៨) | (១៧.៤៥៦) |
| **ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ** | ៣៧.២៣៩ | ១៥១.៨២៤ | (៤.០២៨) | (១៦.៣២១) |
| | | | | |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៤០.១០៣) | - | ៧៤.០៦៧ |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | ៣៧.២៣៩ | ១១១.៧២១ | (៤.០២៨) | ៥៧.៧៤៦ |

## ៦. សកម្មភាពសំខាន់ៗរបស់បុគ្គលិក

### ៦.១ ការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក



ការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលបុគ្គលិកគឺជាអត្តសញ្ញាណពិសេសរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន អិលធីឌី**។ ជាមួយនឹងកម្មវិធីបណ្តុះបណ្តាលដែលរៀបចំឡើងដោយផ្ទាល់របស់ **ហ្វាមើរ ហ្វាយនែ** បានផ្តល់ឱកាសបណ្តុះបណ្តាលទាំងនេះទៅកាន់បុគ្គលិកទាំងអស់ ហើយពួកគេអាចធ្វើការជ្រើសរើសកម្មវិធីបណ្តុះបណ្តាលដែលសមស្របដើម្បីអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាព របស់ពួកគេផងដែរ។ គ្រឹះស្ថានបានបែងចែកការបណ្តុះបណ្តាលបុគ្គលិកមាន ៤ ប្រភេទ៖

**១-ការបណ្តុះបណ្តាលទៅលើគោលការណ៍និងនិតិវិធី:** ការបណ្តុះបណ្តាលនេះ ធ្វើឡើងសំរាប់បុគ្គលិកថ្មី

**២-ការបណ្តុះបណ្តាលលើប្រធានបទជាក់លាក់:** វគ្គបណ្តុះបណ្តាលនេះ គឺផ្តោតជាសំខាន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់បុគ្គលិកនាពេលបច្ចុប្បន្ន ក៏ដូចជាសំរាប់ទៅថ្ងៃអនាគត ដោយបង្កើនសមត្ថភាពរបស់បុគ្គលិកតាមរយៈការសិក្សា ដែលជាទូទៅធ្វើតាមរយៈការកែប្រែនូវឥរិយាបថ ឬបង្កើននូវចំនេះដឹង និងជំនាញរបស់បុគ្គលិក។

**៣-ការបណ្តុះបណ្តាលបន្ថែម:** វគ្គបណ្តុះបណ្តាលនេះ ផ្តោតទៅលើចំណុចខ្សោយរបស់បុគ្គលិកម្នាក់ៗ ឬក៏នាយកដ្ឋានមួយរបស់ក្រុមហ៊ុន ក្រោយពេលដែលបានផ្តល់ការបណ្តុះបណ្តាលរួចហើយ។ អ្នកបណ្តុះ បណ្តាលនឹងធ្វើការបំពេញនូវព័ត៌មាន ឬឯកសារដែលខ្វះខាត ក្រោយពេលដែលបុគ្គលិកបានចូលរួមនៅក្នុងការបណ្តុះបណ្តាល។

**៤-ការបណ្តុះបណ្តាលដោយស្ថាប័នខាងក្រៅ:** វគ្គបណ្តុះបណ្តាលនេះ គឺសំរាប់វគ្គលើ ការគ្រប់គ្រងទៅលើហានិភ័យ វិធីសាស្រ្តសវនកម្មផ្ទៃក្នុង វិធិសាស្រ្តក្នុងការលក់ បណ្តុះបណ្តាលលើអ្នកបណ្តុះបណ្តាលផ្ទៃកពន្ធដា ហើយនិងការគ្រប់គ្រងទូទៅជាដើម ដែលបង្រៀនដោយអ្នកបណ្តុះបណ្តាលមានជំនាញខាងធនាគារនិងមីក្រូហិរញ្ញវត្ថុ និងបណ្តុះបណ្តាលថ្នាក់អន្តរជាតិ។

ការបណ្តុះបណ្តាលរបស់យើងមានមូលដ្ឋានទៅលើការអនុវត្តន៍ជាក់ស្តែង តំរូវការ សកម្មភាពជាក្រុម ការចែករំលែកបទពិសោធន៍ និងសកម្មភាពបណ្តុះបណ្តាលដ៏ច្នៃប្រឌិត។ យើងតែងតែយកចិត្តទុកដាក់ខ្ពស់ ក្នុងការទទួលយកសំណើរពីបុគ្គលិក ក្នុងការបង្កើតឬស្វែងរកវិធីសាស្រ្តថ្មី ក្នុងការបណ្តុះបណ្តាល និងផ្តល់ការគាំទ្រដល់បុគ្គលិកក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេ។









(សកម្មភាពបុគ្គលិកក្នុងពេលចូលរួមវគ្គបណ្តុះបណ្តាល)

## ៦.២ ការលើកទឹកចិត្តបុគ្គលិកតាមរយៈការដើរកំសាន្តប្រចាំឆ្នាំ




(ដំណើរកំសាន្តប្រចាំឆ្នាំ ២០២០ នៅខេត្តកោះកុង)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** លើកកម្ពស់វប្បធម៌នៃការគោរព និងទំនាក់ល្អរវាងបុគ្គលិក និងបុគ្គលិក ព្រមទាំងជាយុទ្ធសាស្ត្រ ពង្រឹងការរួមចំណែករបស់បុគ្គលិក។ ព្រឹត្តិការណ៍ក្រុមហ៊ុនដែលមានការរៀបចំបានល្អ អាចផ្សារភ្ជាប់ទៅនឹងវប្បធម៌របស់គ្រឹះស្ថាន ហើយក៏អាចជាមធ្យោបាយដ៏មានឥទ្ធិពលមួយក្នុងការជំរុញ និងលើកទឹកចិត្តបុគ្គលិកផងដែរ។

ដំណើរកម្សាន្តនិងកម្មវិធីផ្សេងៗប្រចាំឆ្នាំ អាចបង្កើតនូវភាពស្និទ្ធស្នាលរវាងបុគ្គលិកគ្រប់រូប ពីគ្រប់ផ្នែកនៅក្នុងគ្រឹះស្ថាន។ ភាពស្និទ្ធស្នាលទាំងនោះហើយ ដែលជាកត្តាជំរុញឲ្យបុគ្គលិកធ្វើការងារប្រកបដោយប្រសិទ្ធភាព និងបង្កើនគំនិតច្នៃប្រឌិត។ ការរៀបចំកម្មវិធីសម្រាប់បុគ្គលិក ពិតជាផ្តល់ផលប្រយោជន៍ និងផ្តល់តម្លៃសក្តិសមក្នុងគោលបំណងឲ្យបុគ្គលិកបានទទួលនូវភាពសប្បាយរីករាយ និងចូលរួមចំណែកទាំងអស់គ្នា។

នៅថ្ងៃទី០៩ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ **ហ្វាមើរ ហ្វាយនែន** បានរៀបចំដំណើរកំសាន្តប្រចាំឆ្នាំ ដើម្បីអបអរសាទរសមិទ្ធិផលការងារប្រចាំឆ្នាំ២០២០ ដោយមានការចូលរួមពីថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់ នៅតំបន់ទេសចរណ៍សំខាន់មួយចំនួននៅក្នុងខេត្តកោះកុង ដែលជាកន្លែងមានទេសភាពស្រស់ស្អាត មានខ្យល់អាកាសល្អបរិសុទ្ធសម្រាប់ឱ្យបុគ្គលិកសម្រាកលំហែកាយ និងលេងល្បែងកសាងក្រុម(Team Building)ក្រោយពីបានបំពេញការងារអស់រយៈពេលមួយឆ្នាំកន្លងមកប្រកបដោយភាពសប្បាយរីករាយ។




(សកម្មភាពនីនៃដំណើរកំសាន្តប្រចាំឆ្នាំ ២០២០ នៅខេត្តកោះកុង)

## ៧.តំបន់ប្រតិបត្តិការ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** មានបណ្តាញប្រតិបត្តិការមួយកន្លែងស្ថិតនៅអគារលេខ ១៤៦៥ ផ្លូវជាត់លេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ គ្រឹះស្ថានបានផ្តល់សេវាប្រាក់កម្ចីទៅដល់ខេត្ត-ក្រុងចំនួន ០៤ ដែលរួមមានទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។




(ផែនទីបង្ហាញតំបន់ប្រតិបត្តិការរបស់គ្រឹះស្ថាន)

## ៨. ដៃគូររបស់ហ្វាមើរ ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ហ្វាមើរ ហ្វាយនែន** មានដៃគូរសហការមួយចំនួនដើម្បីសំរួលដល់ដំណើការរបស់គ្រឹះស្ថានឱ្យកាន់តែមានភាពរលូន និងដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាកម្មជូនអតិថិជនឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

| | |
|---|---|
| អាសយដ្ឋាន៖ | ផ្ទះលេខ ១៤៦៥ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ទូរស័ព្ទលេខ៖ | +៨៥៥(0)២៣-៦៣៦៣ ១៧២ |
| អ៊ីម៉ែល: | info@farmerfinance.com.kh |
| ហ្វេសបុក: | www.facebook.com/farmerfinanceltd |

ទូរស័ព្ទលេខ : ៨៥៥(០)២៣ ៦៣៦៣ ១៧២
អ៊ីម៉ែល : info@farmerfinance.com.kh
ហ្វេសប៊ុក : www.facebook.com/farmerfinanceltd
អាសយដ្ឋាន : ផ្ទះលេខ ១៤៦៥ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ